**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និងកីឡា**
លេខ: ១៥ អយក.សណន

# សេចក្តីណែនាំ
# ស្តីពី
# ការចូលរួមសន្សំសំចៃការប្រើប្រាស់ប្រេងឥន្ធនៈ និងអគ្គិសនី

ក្នុងបរិបទដែលតម្លៃប្រេងឥន្ធនៈកើនឡើងយ៉ាងគំហុកជាសកល ដោយសារបញ្ហាសង្គ្រាមនៅមជ្ឈិមបូព៌ា និងតម្រូវការប្រើប្រាស់អគ្គិសនីមានការកើនឡើងខ្លាំង ដោយសារអាកាសធាតុក្តៅ បានកំពុងប៉ះពាល់ដោយផ្ទាល់ដល់ការប្រើប្រាស់ថាមពលជាទូទៅ រាជរដ្ឋាភិបាលកម្ពុជាបានចេញសារាចរ ស្តីពី «វិធានការសន្សំសំចៃលើការប្រើប្រាស់ប្រេងឥន្ធនៈ និងអគ្គិសនី» ។ ដើម្បីចូលរួមអនុវត្តសារាចររបស់រាជរដ្ឋាភិបាល ក្រសួងអប់រំ យុវជន និងកីឡា សូមណែនាំដល់ថ្នាក់ដឹកនាំ បុគ្គលិកអប់រំទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ គណៈគ្រប់គ្រង លោកគ្រូ អ្នកគ្រូ និស្សិត និងសិស្សានុសិស្ស នៅតាមគ្រឹះស្ថានសិក្សាសាធារណៈ និងឯកជនគ្រប់កម្រិត ឱ្យចូលរួមអនុវត្តវិធានការសន្សំសំចៃការប្រើប្រាស់ប្រេងឥន្ធនៈ និងអគ្គិសនី ដូចខាងក្រោម៖

- លើកទឹកចិត្តបុគ្គលិកអប់រំ គ្រូបង្រៀន និស្សិត និងសិស្សានុសិស្ស ឱ្យជ្រើសរើសមធ្យោបាយធ្វើដំណើរសាធារណៈ មធ្យោបាយធ្វើដំណើររួមគ្នា និងជ្រើសរើសមធ្យោបាយធ្វើដំណើរដែលប្រើប្រាស់ប្រេងឥន្ធនៈតិច ឬមិនប្រើប្រាស់ប្រេងឥន្ធនៈ
- កាត់បន្ថយជាអតិបរមាក្នុងការរៀបចំ សិក្ខាសាលានិងកិច្ចប្រជុំ ដែលត្រូវធ្វើដំណើរឆ្ងាយ
- លើកទឹកចិត្តឱ្យរៀបចំ សិក្ខាសាលានិងកិច្ចប្រជុំ តាមប្រព័ន្ធអនឡាញ
- លើកទឹកចិត្តបុគ្គលិកអប់រំ និងគ្រូបង្រៀន ឱ្យប្រើប្រាស់ថាមពលអគ្គិសនីប្រកបដោយប្រសិទ្ធភាព ដោយត្រូវចៀសវាងការប្រើប្រាស់ឧបករណ៍បរិក្ខារអគ្គិសនីណាដែលមិនចាំបាច់
- បិទភ្លើង កង្ហារ ម៉ាស៊ីនត្រជាក់ កុំព្យូទ័រ ម៉ាស៊ីនហ្វូតូកូពី និងឧបករណ៍បរិក្ខារអគ្គិសនីផ្សេងៗ បន្ទាប់ពីបញ្ចប់ការងារ ឬនៅពេលមិនប្រើប្រាស់
- ប្រើប្រាស់ម៉ាស៊ីនត្រជាក់ និងឧបករណ៍បរិក្ខារអគ្គិសនីផ្សេងៗ តាមការណែនាំរបស់ក្រសួងរ៉ែ និងថាមពល ដូចជាការកំណត់សីតុណ្ហភាពម៉ាស៊ីនត្រជាក់ក្នុងកម្រិតសមស្រប
- ប្រើប្រាស់ពន្លឺធម្មជាតិឱ្យបានច្រើនជាអតិបរិមា នៅពេលមានលក្ខខណ្ឌអនុគ្រោះ (ដូចជា បើកទ្វារ និងបង្អួច)
- ណែនាំ លើកទឹកចិត្ត និងបង្រៀន និស្សិតនិងសិស្សានុសិស្សឱ្យចូលរួមនិងមានទម្លាប់សន្សំសំចៃការប្រើប្រាស់អគ្គិសនី
- គ្រប់អង្គភាព និងគ្រឹះស្ថានសិក្សាទាំងអស់ ត្រូវចូលរួមផ្សព្វផ្សាយសារៈសំខាន់នៃការសន្សំសំចៃអគ្គិសនី និងត្រូវអនុវត្តវិធានការសន្សំសំចៃការប្រើប្រាស់ប្រេងឥន្ធនៈ និងអគ្គិសនី ដោយស្មារតីទទួលខុសត្រូវខ្ពស់ និងត្រូវចូលរួមត្រួតពិនិត្យជាប្រចាំ។

ក្រសួងអប់រំ យុវជន និងកីឡា សង្ឃឹមយ៉ាងមុតមាំថា ថ្នាក់ដឹកនាំ បុគ្គលិកអប់រំ និងគ្រឹះស្ថានសិក្សាទាំងអស់ នឹងចូលរួមអនុវត្តសេចក្តីណែនាំនេះប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ និងដាក់ចេញនូវការណែនាំផ្សេងៗទៀតដែលស្របតាមស្ថានភាពជាក់ស្តែងរបស់អង្គភាព និងគ្រឹះស្ថានសិក្សា ដើម្បីរួមចំណែកកាត់បន្ថយការចំណាយ និងប្រើប្រាស់ប្រេងឥន្ធនៈ និងអគ្គិសនី ឱ្យមានប្រសិទ្ធភាពខ្ពស់។

ថ្ងៃចន្ទ ៥ កើត ខែចេត្រ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩

រាជធានីភ្នំពេញ ថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២៦

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

បណ្ឌិតសភាចារ្យ **ហង់ជួន ណារ៉ុន**

**ចម្លងជូន៖**

-អគ្គលេខាធិការដ្ឋាន
-អគ្គាធិការដ្ឋាន និងគ្រប់អគ្គនាយកដ្ឋាន
-អង្គភាពក្រោមឱវាទីស្តីការក្រសួង
-មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត
-គ្រឹះស្ថានសិក្សា "ដើម្បីអនុវត្ត"
-កាលប្បវត្តិ
-ឯកសារ ខុទ្ទកាល័យ